តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១១៥

ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩

សាលដីកា

លេខ: ០៩ (I)

ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រមរបាយការណ៍

៥.លោកស្រី [redacted] ចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

នៅលើបណ្តឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] មុន្នីរ័ត្ន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រ IV "រ.ឧ" ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនជាប់ចោទ៖**

១.ឈ្មោះ [redacted] រស្មី ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលើរ ទោសពីមុនគ្មាន ។



Scanned with CamScanner

-ឃុំខ្លួនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧

២.ឈ្មោះ [redacted] មុន្នីរ័ត្ន ភេទប្រុស កើតនៅថ្ងៃទី០៨ ខែវិច្ឆកា ឆ្នាំ១៩៩៥ ជាតិខ្មែរ មុខរបរបុគ្គលិកកាស៊ីណូ Good luck ទីកន្លែងកំណើត និងទីលំនៅមុនពេលឃុំខ្លួននៅ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ (អ្នកប្តឹងសាទុក្ខ)

-ឃុំខ្លួនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧។

មេធាវីការពារសិទ្ធិ៖ លោក [redacted] តារាវិនាទ។

**ជាប់ចោទពីបទ:** ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១៣ រហូតដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា ៤៥ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.ឈ្មោះ [redacted] ហាយវ៉ាង ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិវៀតណាម ទីកន្លែងកំណើត និងទីលំនៅមុនពេលឃុំខ្លួននៅ [redacted] ប្រទេសវៀតណាម ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

**ជាប់ចោទពីបទ:** ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសមានចែងឲ្យ ផ្តន្ទាទោសមាត្រាបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង១៧ និង៣០នាទី អ្នករត់តាក់ស៊ីស្វាយរៀង ឈ្មោះ [redacted] សុផាន បានរាយការណ៍ជូនកម្លាំងកងរាជអាវុធហត្ថខេត្តស្វាយរៀង ថាមានគេផ្ញើរប្រអប់មួយតាមរថយន្តរបស់ខ្លួន ហើយប្រអប់នេះមើលទៅមិនស្រួលទេ ពេលដែលសមត្ថកិច្ចកងរាជអាវុធហត្ថ ចុះពិនិត្យមើល និងបើកប្រអប់ឃើញមាន ម្សៅក្រាមពណ៌សថ្លា០១កញ្ចប់ និងសំបកថង់សម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួនទៀត។ កម្លាំងជំនាញកងរាជអាវុធហត្ថខេត្តក៏បានប្រតិបត្តិការតាមច្បាប់មុខសញ្ញាជនសង្ស័យ ដែលមកទទួលអីវ៉ាន់នេះនៅវេលាម៉ោង១៨ និង៤០នាទី មុខកាស៊ីណូក្រោន ស្ថិតនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង សមត្ថកិច្ចបានទូរស័ព្ទឲ្យ មុខសញ្ញាជនសង្ស័យបានដើរមករកឡានតាក់ស៊ី ពេលនោះសមត្ថកិច្ចបានចាប់ខ្លួនជនសង្ស័យឈ្មោះ [redacted] មុន្នីរ័ត្ន និងឈ្មោះ [redacted] ហាយវ៉ាង ពេលនោះ ឈ្មោះ [redacted] មុន្នីរ័ត្ន បានសហការជាមួយសមត្ថកិច្ចផ្តល់មុខសញ្ញា គ្រឿងញៀន និងជាម្ចាស់អីវ៉ាន់ឈ្មោះ [redacted] រស្មី។ នៅវេលាម៉ោង ២០ និង៣០ នាទី

Scanned with CamScanner

ឈ្មោះ [redacted] រស្មី បានបង្ហាញខ្លួន កម្លាំងកងរាជអាវុធហត្ថបានចុះប្រត្តិបត្តិការចាប់ខ្លួនឈ្មោះ [redacted] រស្មី នាំមកសាកសួរនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តស្វាយរៀង ដើម្បីធ្វើការសាកសួរ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការ ចាត់ការតាមច្បាប់ កាលពីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៧។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩៦ "ង" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសលើឈ្មោះ [redacted] រស្មី ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ (ដែលមានសារតាជាតិខាងលើ) ដាក់ពន្ធនាគារចំនួន ០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលអំឡុងឆ្នាំ២០១៣ រហូតដល់ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ផ្តន្ទាទោសលើឈ្មោះ [redacted] មុន្នីរ័ត្ន ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិ (ដែលមានសារតាជាតិខាងលើ) ដាក់ពន្ធនាគារចំនួន០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល ពីបទៈជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលអំឡុងឆ្នាំ២០១៣ រហូតដល់ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ផ្តន្ទាទោសលើ [redacted] ហាយវ៉ាង ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិវៀតណាម (ដែលមានសារតាជាតិខាងលើ) ដាក់ពន្ធនាគារចំនួន០៦(ប្រាំមួយ)ខែ តែទោសនេះត្រូវអនុវត្តទោសព្យួរ ពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤.វត្ថុចាប់យកមានម្សៅក្រាមពណ៌សថ្លាប្រភេទមេតំហ្វេតាមីន ទម្ងន់១១.៤៦ក្រាម គិតទាំងសំបកវេចខ្ចប់ និងថង់សម្រាប់វេចខ្ចប់មួយចំនួនធំ សម្រេចរឹបអូស និងបំផ្លាញចោល។

៥.វត្ថុចាប់យកមាន ម៉ូតូម៉ាកសេ ១២៥ ពណ៌ខ្មៅ ស្លាកលេខ ស្វាយរៀង ១I ៦៨ ៩៥ ចំនួន០១គ្រឿង ដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ស្រីម៉ៅ សម្រេចប្រគល់ឲ្យឈ្មោះ ហិន ស្រីម៉ៅ គ្រប់គ្រងជាកម្មសិទ្ធិវិញ។

៦.វត្ថុចាប់យកមានៈ ទូរស័ព្ទម៉ាកOUKITEL ចំនួន០១គ្រឿង ទូរស័ព្ទ IPHONE ចំនួន០១គ្រឿង ទូរស័ព្ទ NOKIA ចំនួន០១គ្រឿង សម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

Scanned with CamScanner

៧.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រស្មី , ឈ្មោះ [redacted] មុន្នីរ័ត្ន និងកំបាំងមុខ ឈ្មោះ [redacted] ហាវ៉ាង។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ២៩ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] មុន្នីរ័ត្ន មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៦ "ង" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៧ ក្រIV "រ.ន" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ២៩ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] មុន្នីរ័ត្ន ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩៦ "ង" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀងត្រង់ចំណុចទី២ នៃសេចក្តីសម្រេច ទុកជាបានការដដែល ។

៣.សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី២៨ ខែវិច្ឆកា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ។

ទុកសិទ្ធិប្តឹងទាស់តាមកំណត់ច្បាប់ ។

-បានឃើញសារណាការពាររបស់លោក ទន់ តារាវិនាន មេធាវីការពារឲ្យឈ្មោះ [redacted] មុន្នីរ័ត្ន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៦ "ង" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀងត្រង់ចំណុចទី២ នៃសេចក្តីសម្រេចទុកជាបានការដដែលនោះគឺមានលក្ខណៈត្រឹមត្រូវ តាមច្បាប់ហើយ។ ដោយផ្អែកតាមសំអាងហេតុ របស់សាលាឧទ្ធរណ៍បានបញ្ជាក់ថាឈ្មោះ [redacted] រស្មី ដែលជាបក្សពួក បានឆ្លើយនៅសមត្ថកិច្ចថា ខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀន ជាមួយជនជាប់ចោទឈ្មោះ [redacted] មុន្នីរ័ត្ន ជាច្រើនលើក។ នាពេលមួយខ្លួនបានសួរឈ្មោះ រ័ត្ន ថាមានស្គាល់អ្នកលក់គ្រឿងញៀនទេ ឈ្មោះ រ័ត្ន បានឆ្លើយថាស្គាល់ឈ្មោះ អ៊ូក ដែលរស់នៅកៀនស្វាយជាអ្នកលក់ ពេលនោះខ្លួនក៏បានឲ្យឈ្មោះ រ័ត្ន



Scanned with CamScanner

ទាក់ទងទិញពីឈ្មោះ អ៊ូក ចំនួន០៣នាក់ ជី តម្លៃ ២៨០ (ពីររយប៉ែតសិប) ដុល្លារអាមេរិក ហើយឱ្យអ៊ូកផ្ញើតាមតាក់ស៊ីដោយឈ្មោះ អ៊ូក បានដាក់ទូរស័ព្ទលេខខ្លួន និង លេខរបស់ឈ្មោះ រ័ត្ន ។ ដូច្នេះបញ្ជាក់បានថាអំពើរបស់ជនជាប់ចោទពិតជាមានភស្តុតាង ស៊ីសង្វាក់ និងទំនាក់ទំនងជួញដូរគ្រឿងញៀន ជាមួយបក្សពួកខ្លួន និងស៊ីសង្វាក់ទៅនឹងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌នូវសារធាតុញៀន និងសកម្មភាពមួយចំនួនទៀតដែលបានបំភ្លឺនៅក្នុងសំអាងហេតុស្រាប់ដូចក្នុងចំនុច ២,៣,៤,៥,៦ នោះស្រាប់។

## តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជំរះសម្រេច

១-ទទួលបណ្តឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] មុន្នីរ័ត្ន ទុកជាត្រឹមត្រូវតាមទម្រង់ តែផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៧ ក្រIV "រ.ន" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

+ជនជាប់ចោទឈ្មោះ [redacted] មុន្នីរ័ត្ន ឆ្លើយថាខ្ញុំបានកើតនៅថ្ងៃទី០៨ ខែវិច្ឆកា ឆ្នាំ១៩៩៥ មុខរបរបុគ្គលិកកាស៊ីណូ ហ្គូត ឡាក់ សព្វថ្ងៃខ្ញុំជាប់ឃុំនៅពន្ធនាគារ ខេត្តស្វាយរៀង ក្នុងរឿងនេះខ្ញុំមិនបានប្រព្រឹត្ត ខ្ញុំទុកសិទ្ធិអោយមេធាវីខ្ញុំធ្វើសេចក្តីសន្និដ្ឋាន ។

+លោកមេធាវី [redacted] តារាវិនាន ការពារជនជាប់ចោទឈ្មោះ [redacted] មុន្នីរ័ត្ន ធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្ញុំប្តឹងសាទុក្ខមកនេះគឺគាត់មិនសុខចិត្តការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍មិនមានភាពយុត្តិធម៌ចំពោះគាត់ ។

តាមអង្គហេតុថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] រស្មី បានអោយកូនក្តីខ្ញុំទៅទទួល ឥវ៉ាន់ពីឡានតាក់ស៊ីពេលទៅដល់មិនទាន់បានទទួលផងត្រូវប៉ូលីសចាប់គាត់ ហើយគាត់ឆ្ងល់ថាចាប់រឿងអ្វី ។

ក្នុងរឿងនេះកូនក្តីខ្ញុំសហការណ៍ជាមួយសមត្ថកិច្ចដើម្បីចាប់ខ្លួនឈ្មោះ [redacted] រស្មី ហេតុអ្វីបានជាសមត្ថកិច្ចចាប់កូនក្តីខ្ញុំទៅវិញ ។ ការជំរះសាលាដំបូងក៏ដូចសាលាឧទ្ធរណ៍កាត់ក្តីមិនបានពិចារណាទៅលើអង្គហេតុអោយបានច្បាស់លាស់ទើបកូនក្តីខ្ញុំមិនសុខចិត្តព្រោះរឿងនេះមិនមានភស្តុតាងត្រឹមត្រូវ ។

សំណូមពរ: មេត្តាសម្រេចដោះលែងកូនក្តីខ្ញុំអោយរួចផុតពីបទចោទដោយមិនបាច់បង្វិល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

**សំអាងហេតុ**

**តុលាការកំពូល**

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] មុន្នីរ័ត្ន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទបានលើកឡើងអះអាងថា កូនក្តីខ្លួនឈ្មោះ [redacted] មុន្នីរ័ត្ន មិនបានជាប់ពាក់ព័ន្ធនឹងអំពើល្មើសនេះទេ កូនក្តីខ្លួនគ្រាន់តែជាអ្នកទៅយកអីវ៉ាន់ពីឡានតាក់ស៊ីយកទៅឱ្យឈ្មោះ [redacted] រស្មី តែប៉ុណ្ណោះ ដោយសារតែកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ១៧ និង ៣០ នាទីនោះ ឈ្មោះ [redacted] រស្មី បានប្រាប់ឱ្យកូនក្តីខ្លួនទៅយកអីវ៉ាន់ពីឡានតាក់ស៊ីមួយ ប៉ុន្តែឈ្មោះ [redacted] រស្មី មិនបានប្រាប់ថាជាអីវ៉ាន់អ្វីនោះទេ ហើយកូនក្តីខ្លួនក៏មិនបានដឹងថានៅក្នុងអីវ៉ាន់នោះជាអ្វីនោះដែរ បន្ទាប់ពីកូនក្តីខ្លួនមកដល់កន្លែងទទួលអីវ៉ាន់ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនកូនក្តីខ្លួនតែម្តង ។ ដូច្នេះ បើគ្រាន់តែកូនក្តីខ្លួនមកទទួលអីវ៉ាន់ពីអ្នកដទៃដែលគេពឹងឱ្យមកជួយយកជំនួសគេសោះ ក៏ជាបទល្មើសព្រហ្មទណ្ឌដែរនោះ តើគ្រប់បុគ្គលដែលធ្វើការលក់ប្រតិបត្តិការទំនិញទាំងអស់តាមប្រព័ន្ធអនឡាញជាដើម ហ៊ានបញ្ជាទិញលក់ទំនិញទៀតដែរឬទេ? ម្យ៉ាងវិញទៀតកូនក្តីខ្លួនពុំដែលប្រព្រឹត្តអំពើជួញដូរសារធាតុញៀនម្តងណាទេ គឺធ្លាប់តែប្រើប្រាស់ថ្នាំញៀនតែប៉ុណ្ណោះ។ មួយវិញទៀត នៅពេលកងកម្លាំងមានសមត្ថកិច្ចចាប់ឃាត់ខ្លួនកូនក្តីរបស់ខ្លួន កូនក្តីរបស់ខ្លួនក៏បានសហការជាមួយសមត្ថកិច្ចទៀតផងនោះ គឺជា សេចក្តីសន្និដ្ឋានមិនមានមូលដ្ឋានអង្គច្បាប់ជាក់លាក់ណាមួយដូចមានបញ្ញត្តក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីមូលហេតុនៃបណ្តឹងសាទុក្ខនោះឡើយ ។ ម្យ៉ាងទៀត សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីគ្រាន់តែលើកឡើងអះអាងតាមតែការណែនាំរបស់ជនជាប់ចោទកូនក្តីរបស់ខ្លួនប៉ុណ្ណោះ ។

៣-យល់ឃើញថា សេចក្តីសម្រេច និងសំអាងហេតុក្នុងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តី និងលើកឡើងនូវសំអាងហេតុសព្វគ្រប់ សមស្រប តាមអង្គហេតុ ភស្តុតាង និងអង្គច្បាប់ហើយ តុលាការកំពូលយល់ស្របនឹងសេចក្តីសម្រេច និងសំអាងហេតុទាំងអស់នេះរបស់សាលាឧទ្ធរណ៍ភ្នំពេញ ។

៤-យល់ឃើញថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់ ក៏ដូចជាសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់តំណាងមហាអយ្យការអមតុលាការកំពូលដែរ បានលើកឡើងថា សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨១ "ង" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់សេចក្តីសម្រេចចំណុចទី២ ទុកជាបានការដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដោយផ្អែកលើអង្គហេតុ ភស្តុតាងស៊ីចង្វាក់គ្នា

Scanned with CamScanner

ដែលបានលើកឡើង ក្នុងសាលក្រមសាលាដំបូងខេត្តស្វាយរៀង និងក្នុងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ និងប្តឹង សុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៩ ក្រIVឧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ គឺជាសេចក្តីសន្និដ្ឋានផ្អែកលើមូលដ្ឋានអង្គហេតុពិត ភស្តុតាង និងអង្គច្បាប់ច្បាស់លាស់ សមស្រប អាចឱ្យតុលាការផ្អែកលើលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានក្នុងការពិចារណា វិនិច្ឆ័យសម្រេចសេចក្តីបាន ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIVឧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] មុន្នីរ័ត្ន ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIVឧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០២០។

Scanned with CamScanner